**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| **តុលាការខេត្តកំពង់ធំ** |
| សាលក្រម |
| លេខ ៣៥ "ក" ចុះថ្ងៃទី ២៨ |
| ខែ កក្កដា ឆ្នាំ ២០០៥ |
| សំណុំរឿង |
| លេខ ៦២ ចុះថ្ងៃទី ២៧ |
| ខែ មេសា ឆ្នាំ ២០០៥ |

**តាមនាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

សាលក្រមនេះបានចូលស្ថាពរចាប់តាំងពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ តទៅ
ដោយហេតុគ្មានបណ្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។
កំពង់ធំ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥
ប្រធានតុលាការខេត្ត
[redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង **ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តី** ។

-រវាងដើមចោទ ត ជ ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិបឹងរលំ ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្តីឈ្មោះ ច ទ មានកូន ០៤នាក់ ឪពុកឈ្មោះ ត ហ "ស" ម្តាយឈ្មោះ ស ន "រ" ។

-និង ចុងចម្លើយឈ្មោះ ច ទ ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិបឹងរលំ ឃុំឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ ត ជ មានកូន ០៤នាក់ ឪពុកឈ្មោះ ឈ ទ "ស" ម្តាយឈ្មោះ ភ គ "រ" ។

**អង្គហេតុមានដូចតទៅ**

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ ត ជ បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ច ទ ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ច ទ ត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៨៦ ការរស់នៅជាមួយគ្នាបានកូន ០៤នាក់ពុំសូវមានសេចក្តីសុខទេ ដោយប្តីប្រើអំពើហឹង្សាមកលើខ្លួនញឹកញាប់មិនអាចទ្រាំរស់នៅជាប្តីប្រពន្ធនឹងគ្នាបានទេ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះ លេខ ២៧៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៣៧៥ ចុះថ្ងៃទី ២១ ខែ មិថុនា

ឆ្នាំ ២០០៥ ។

<u>**នារីពលសទ៩នាការ**</u>

-ដើមចោទឈ្មោះ ត ជ បានឆ្លើយបញ្ជាក់ថា ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ច ខ ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ១៩៨៦ មករួមរស់នៅជាមួយគ្នាមានកូន ០៤នាក់ ទី១ ឈ្មោះ ខ ខ ភេទប្រុស អាយុ ១៧ឆ្នាំ កូនទី២ ឈ្មោះ ខ ខន ភេទប្រុស អាយុ ១៥ឆ្នាំ កូនទី៣ ឈ្មោះ ខ ខឧ ភេទប្រុស អាយុ ០៨ឆ្នាំ និង កូនទី៤ ឈ្មោះ ខ ត ភេទស្រី អាយុ ០៦ឆ្នាំ ។ ការរួមរស់នៅជាមួយគ្នាកន្លងមកចេះតែរកាំរកុះជាញឹកញាប់ តែខ្លួនខំទ្រាំរស់នៅជាមួយគ្នា ព្រោះអាណិតកូន ។ លុះដល់ខែ ០១ ឆ្នាំ ២០០៤ ប្តីបានយកប្រាក់ចំនួន ៦០០.០០០រ៉ុ០០ ទៅទិញគោឈ្មោលចាស់ ០១ក្បាល ខ្លួនបានស្តីបន្ទោសប្តីថា ទិញគោមិនចេះមើលឱ្យបានច្បាស់លាស់ទេ ពេលនោះប្តីខឹងខ្លាំង ស្ទុះមកវាយខ្លួនទាំងកំរោល មិនតែប៉ុណ្ណោះពេលប្តីផឹកស្រាស្រវឹងមកដល់ផ្ទះបោកចានឆ្នាំង វាយកូនគ្មានត្រាប្រណីប្រើអំពើហឹង្សាមកលើខ្លួនជាច្រើនដងមិនអាចទ្រាំរួមរស់នៅជាប្តីប្រពន្ធតទៅទៀតបានទេ ។ ទ្រព្យសម្បត្តិដើមរបស់ខ្លួនមាន ដីលំនៅដ្ឋានទំហំ ២០ម x ១៦០ម ស្ថិតនៅភូមិបឹងរលំ ដីស្រែបីកន្លែង ស្រែទី១ ទំហំ ៣០ម x ៤០ម ស្ថិតនៅតំបន់ពោធិបាក់ដៃ ក្នុងភូមិបឹងរលំ ស្រែទី២ទំហំ ១៥ម x ១៥ម ស្ថិតនៅតំបន់ត្រពាំងកាញ់ ភូមិបឹងរលំ ស្រែទី៣ ទំហំ ២០ម x ៣០ម ស្ថិតនៅតំបន់ចាជ្រុំនៅក្នុងភូមិបឹងប្រា ឃុំឈើទាល ដីចំការទំហំ ១០ម x ៥០ម ស្ថិតនៅភូមិបឹងរលំ គោឈ្មោល០១ក្បាល ឯទ្រព្យសម្បត្តិរួមមានផ្ទះឈើប្រក់ក្បឿង ០២ខ្នង ទំហំ ០៧ម គុណ ០៨ម សាងសង់លើដីទ្រព្យសម្បត្តិដើមរបស់ខ្លួន មាសសុទ្ធទម្ងន់ ០៥ជី រទេះគោ ០២គ្រឿង ដីចំការទំហំ ០៨ម x ៤០ម ស្ថិតនៅក្បែរផ្ទះ គ្រែដេក ០១គ្រឿង កូនជ្រូក ០១ក្បាល ស្រូវចំនួន ១៦បេ កង់ ០១គ្រឿង គោ ០៤ក្បាល (ឈ្មោល ០២ក្បាល ញី ០២ក្បាល) សំណូមពរសុំលែងលះពីប្តី, សុំគ្រប់គ្រងកូន ០៤នាក់ ទាមទារអាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៣.០០០.០០០រ៉ុ០០ និង ទាមទារចែកទ្រព្យសម្បត្តិរួមតាមច្បាប់ ។

-ចុងចម្លើយឈ្មោះ ច ខ បានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយប្តីឈ្មោះ ត ជ ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ១៩៨៦ មកដូចចម្លើយដើមចោទ ការរួមរស់នៅជាមួយគ្នាកន្លងមកបានកូន ០៤នាក់ កូន ទី១ ឈ្មោះ ខ ខ ភេទប្រុស អាយុ ១៧ឆ្នាំ កូនទី២ ឈ្មោះ ខ ខន ភេទប្រុស អាយុ ១៥ឆ្នាំ កូនទី៣ ឈ្មោះ ខ ខឧ ភេទប្រុស អាយុ ០៨ឆ្នាំ និង កូនទី៤ ឈ្មោះ ខ ត ភេទស្រី អាយុ ០៦ឆ្នាំ ។ ការរួមរស់នៅជាមួយគ្នាកន្លងមកមានរកាំរកូសបន្តិចបន្តួច លុះមកដល់ខែ មករា ឆ្នាំ ២០០៤ ខ្លួនយកប្រាក់ ៦០០.០០០រ៉ុ០០ ទៅទិញគោ ០១ក្បាល ប្រពន្ធបន្ទោសថា ទិញគោមិនល្អ ហើយជេរថែមទៀត ខ្លួនខឹងជេរប្រពន្ធវិញ ពេលនោះប្រពន្ធខឹងក៏ចុះបែកលំនៅសង្វាសទៅនៅផ្ទះបងថ្លៃរហូតមក ។ ទ្រព្យសម្បត្តិដើមមានដីស្រែបីកន្លែង ដីស្រែទី១ទំហំ ១០អារនៅតំបន់គោកជី ដីស្រែទី២ ទំហំ ០៥អារនៅតំបន់កំពង់ត្របែន និង ដីស្រែទី៣ ទំហំ០៩អារនៅតំបន់បឹងរលំ គោឈ្មោល ០១ក្បាល គោញី ០១ក្បាល ឯទ្រព្យសម្បត្តិរួមមានគោ ០៤ក្បាល (ញី ០២ក្បាល ឈ្មោល ០២ក្បាល) ផ្ទះឈើប្រក់ក្បឿង ០២ខ្នង សង់នៅលើដីជាទ្រព្យសម្បត្តិដើមរបស់ប្រពន្ធនៅក្នុងភូមិបឹងរលំ មាសទឹក ១០ទម្ងន់ ០៥ជី នៅលើប្រពន្ធគ្រប់គ្រង រទេះគោ ០២គ្រឿង (រទេះកង់ឡាន ០១គ្រឿង) ដីចំការទំហំ ០៨ម x ៤០ម នៅជាប់ខាងក្រោយផ្ទះ គ្រែដេក ០១គ្រឿង, កូនជ្រូក ០១ក្បាល និង ស្រូវចំនួន ១៦បេ ។ សំណូមពរតុលាការសុំរួមរស់នៅជាមួយប្រពន្ធវិញ តែបើប្រពន្ធមិនព្រមមករួមរស់នៅជាមួយទេ ខ្លួនគ្រប់គ្រងកូន ០៤នាក់ និង រស់នៅលើផ្ទះគ្រប់គ្រងទ្រព្យសម្បត្តិរួម ។

<u>**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា :**</u>

ចំពោះរឿងក្តីនេះអយ្យការស្នើសុំតុលាការសំរេចទៅតាមច្បាប់ ។

CamScanner

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៏ និង ប្តឹងសុំ
-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ ឥ ជ មាន លក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ឈ្មោះ ឥ ជ បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ច ទ ដោយសំអាងហេតុ ថាខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ច ទ ត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៨៦ រស់នៅជាមួយគ្នាបានកូន ០៤នាក់ ពុំសូវបានសេចក្តីសុខទេ ដោយប្តីប្រើអំពើហឹង្សាមកលើខ្លួនញឹកញាប់មិនអាចទ្រាំរស់នៅជាប្តីប្រពន្ធនឹងគ្នាបានទេ ។

-យល់ឃើញថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ពីឆ្នាំ ១៩៨៦ រស់នៅជាមួយគ្នាមានទំនាស់រកាំរកូសនឹងគ្នាជាប្រចាំ រហូតដល់ខែ មករា ឆ្នាំ ២០០៤ ដើមចោទបានចុះបែកលំនៅសង្វាសពីគ្នារហូតគូភាគីស្ម័គ្រចិត្តលែងលះគ្នា ដោយអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា ទ្រព្យសម្បត្តិដើមរបស់ដើមចោទមានដីលំនៅដ្ឋានទំហំ ២០ម x ១៦០ម ស្ថិតនៅភូមិបឹងរលំ ដីស្រែបីកន្លែង ស្រែទី១ ទំហំ ៣០ម x ៤០ម ស្ថិតនៅតំបន់ពោធិបាក់ដៃក្នុងភូមិបឹងរលំ ស្រែទី២ ទំហំ ១៥ម x ១៥ម ស្ថិតនៅតំបន់ត្រពាំងកាញ់ភូមិបឹងរលំ ស្រែទី៣ ទំហំ ២០ម x ៣០ម ស្ថិតនៅតំបន់ចាជ្រុំនៅភូមិបឹងប្រា ឃុំឈើទាល ដីចំការទំហំ ១០ម x ៥០ ស្ថិតនៅភូមិបឹងរលំ និង គោឈ្មោល ០១ក្បាល ឯទ្រព្យសម្បត្តិដើមរបស់ចុងចម្លើយមាន : ដីស្រែប៉ីកន្លែង ដីស្រែទី១ទំហំ ១០អារនៅតំបន់គោកជី ដីស្រែទី២ ទំហំ ០៥អារនៅតំបន់កំពង់ត្របែន និង ដីស្រែទី៣ ទំហំ០៩អារនៅតំបន់បឹងរលំ គោឈ្មោល ០១ក្បាល គោញី០១ក្បាល ។

-យល់ឃើញថា : ទ្រព្យសម្បត្តិរួមប្តីប្រពន្ធរបស់គូភាគីមានផ្ទះឈើប្រក់ស្បឿង ០២ខ្នង ទំហំ ០៧ម x ០៨ម មាសទម្ងន់ ០៥ជី រទេះគោ ០២គ្រឿង ដីចំការទំហំ ០៨មx៤០ម ស្ថិតនៅក្បែរផ្ទះ គ្រែដេក ០១គ្រឿង ស្រូវចំនួន ១៦បេ កង់ ០១គ្រឿង គោឈ្មោល ០២ក្បាល គោញី ០២ក្បាល កូនជ្រូក ០១ក្បាល ។

-យល់ឃើញថា គូភាគីមានកូន ០៤នាក់ ទី១ ឈ្មោះ ទ ទ ភេទប្រុស អាយុ ១៧ឆ្នាំ កូនទី២ ឈ្មោះ ទ ទន ភេទប្រុស អាយុ ១៥ឆ្នាំ កូនទី៣ ឈ្មោះ ទ ទឌ ភេទប្រុស អាយុ ០៨ឆ្នាំ និង កូនទី៤ ឈ្មោះ ទ ត ភេទស្រី អាយុ ០៦ឆ្នាំ គូភាគីបានសុំចិញ្ចឹមគ្រប់គ្រងដូចគ្នា ដូច្នេះតុលាការពិចារណាតាមច្បាប់ ។

-យល់ឃើញថា : ដើមចោទបានសុំឱ្យចុងចម្លើយផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ០៤នាក់ផ្តាច់ចំនួន បីលានរៀល តុលាការពិចារណាតាមច្បាប់ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ ឥ ជ ទុកជាត្រឹមត្រូវ

តាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ ត ៥ និង ចុងចម្លើយឈ្មោះ ច ទ ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ ដាក់កំហុសលើចុងចម្លើយ ។

៣-ឱ្យឈ្មោះនាង ត ៥ ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់កូន ០៤នាក់ គឺទី១ ឈ្មោះ ទ ទ ភេទប្រុស អាយុ ១៧ឆ្នាំ កូនទី២ ឈ្មោះ ទ ទន ភេទប្រុស អាយុ ១៥ឆ្នាំ កូនទី៣ ឈ្មោះ ទ ទខ ភេទប្រុស អាយុ ០៨ឆ្នាំ និង កូនទី៤ ឈ្មោះ ទ ត ភេទស្រី អាយុ ០៦ឆ្នាំឱ្យទៅដើមចោទឈ្មោះ ត ៥ គ្រប់គ្រងចិញ្ចឹមថែរក្សា ។ ទុកសិទ្ធិអោយចុងចម្លើយទៅសួរសុខទុក្ខកូនបានតាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-បង្គាប់អោយចុងចម្លើយឈ្មោះ ច ទ ផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ០៤នាក់ផ្តាច់ចំនួន ១.៥០០.០០០រ៉ុល ឱ្យទៅដើមចោទ បណ្តឹងទាមទារលើសពីនេះត្រូវលើកចោល ។

៦-ប្រគល់ទ្រព្យសម្បត្តិដើមរបស់ដើមចោទមាន : ដីលំនៅដ្ឋានទំហំ ២០ម x ១៦០ម ស្ថិតនៅភូមិបឹងរលំ ដីស្រែ ០៣កន្លែង ស្រែទី១ ទំហំ ៣០ម x ៤០ម ស្ថិតនៅតំបន់ពោធិបាក់ដៃក្នុងភូមិបឹងរលំ ស្រែទី២ទំហំ ១៥ម x ១៥ម ស្ថិតនៅតំបន់ត្រពាំងកញ្ចក់ភូមិបឹងរលំ ស្រែទី៣ ទំហំ ២០ម x ៣០ម ស្ថិតនៅតំបន់ចាជ្រុំនៅភូមិបឹងប្រា ឃុំឈើទាល ដីចំការទំហំ ១០ម x ៥០ ស្ថិតនៅភូមិបឹងរលំ និង គោឈ្មោល ០១ក្បាលឱ្យទៅដើមចោទគ្រប់គ្រងកាន់កាប់គ្រប់គ្រង និង ប្រគល់ទ្រព្យសម្បត្តិរបស់ចុងចម្លើយមានដីស្រែ ០៣កន្លែង ដីស្រែទី១ទំហំ ១០អារ នៅតំបន់គោកជី ដីស្រែទី២ ទំហំ ០៥អារ នៅតំបន់កំពង់ត្របែន និង ដីស្រែ៣ ទំហំ០៥អារនៅតំបន់បឹងរលំ គោឈ្មោល ០១ក្បាល គោញី០១ក្បាលឱ្យទៅចុងចម្លើយគ្រប់គ្រង ។

៧-ទ្រព្យសម្បត្តិរួមប្តីប្រពន្ធមានផ្ទះឈើប្រក់ក្បឿង ០២ខ្នងទំហំ ០៧មx០៨ម មាសទម្ងន់ ០៥ជី, រទេះគោ ០២គ្រឿង, ដីចំការទំហំ ០៨ម x ៤០ម ស្ថិតនៅក្បែរផ្ទះ, គ្រែដេក ០១គ្រឿង, ស្រូវចំនួន ១៦បេ, កង់ ០១គ្រឿង, គោឈ្មោល ០២ក្បាល, គោញី ០២ក្បាល, កូនជ្រូក ០១ក្បាលត្រូវបែងចែកពាក់កណ្តាលម្នាក់តាមមាត្រា ៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៨-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច ទ បង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តីពន្ធហ្វឹង ១.៨០០រ៉ុល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ៉ុល រង្វាន់ប្រគល់ដីកាកោះ ៥.០០០រ៉ុល សរុប ៧.០០០រ៉ុល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ៉ុល ដែលដើមចោទបានបង់រួចហើយ ផុតកំណត់ប្តឹងឧទ្ធរណ៍ឱ្យចុងចម្លើយសងទៅដើមចោទវិញ ។

៩-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមិនសុខចិត្តមានសិទ្ធិឧទ្ធរណ៍ក្នុងរយៈពេល ០២ខែតាមកំណត់ច្បាប់ ។

CamScanner

បានឃើញ
ប្រធានតុលាការខេត្ត
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]